**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍**
លេខ :......៤១៣......អ.ជ.ប.ជ.អ

# សេចក្តីសម្រេចចិត្ត
# នៃកិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
# លើកទី២ ឆ្នាំ២០២២
# ថ្ងៃពុធ ១៥រោច ខែកត្តិក ឆ្នាំខាល ចត្វាស័ក ពុទ្ធសករាជ ២៥៦៦
# ត្រូវនឹងថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២២

កិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទី២ ឆ្នាំ២០២២ បានដំណើរការរយៈពេលមួយព្រឹកពេញ នៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២២ នៅសណ្ឋាគារ វីនីណាប៊ូទិក (VININA BOUTIQUE) ខេត្តព្រះសីហនុ ដោយមានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ប្រធានគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍គ្រប់ក្រសួង ស្ថាប័ន រាជធានី ខេត្ត ក្រុមការងារប្រយុទ្ធនឹងជំងឺអេដស៍ក្រសួង ស្ថាប័ន លេខាធិការដ្ឋានប្រយុទ្ធនឹងជំងឺអេដស៍រាជធានី ខេត្តទាំង២៥ អង្គការអន្តរជាតិ និងអង្គការសង្គមស៊ីវិល មានចំនួនសរុបប្រមាណ ១៥៤រូប។

អង្គប្រជុំទាំងមូល បានធ្វើការគោរពថ្លែងនូវអំណរគុណប្រកបដោយកតញ្ញូតាធម៌ដ៏ជ្រាលជ្រៅបំផុតជូនចំពោះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ដែលបានសម្រេចប្រកបដោយគតិបណ្ឌិតដ៏ខ្ពង់ខ្ពស់ដាក់ចេញនូវវិធានការដ៏មានប្រសិទ្ធភាព ក្នុងការឆ្លើយតបនឹងផលប៉ះពាល់នានាពីវិបត្តិជំងឺកូវីដ-១៩ និងវិបត្តិសង្គ្រាមនៅប្រទេសអ៊ុយក្រែន ដោយរក្សាបាននូវស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច សុខមាលភាពសង្គមរបស់ប្រទេសកម្ពុជាបានយ៉ាងរឹងមាំ និងបានផ្តល់នូវកាលានុវត្តភាពដ៏ចម្បងក្នុងការងារប្រយុទ្ធនឹងជំងឺអេដស៍។

ជាមួយគ្នានេះ អង្គប្រជុំក៏បានធ្វើការថ្លែងអំណរគុណ និងកោតសរសើរចំពោះគ្រប់ស្ថាប័នទាំងថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ អន្តរជាតិ អង្គការសង្គមស៊ីវិល បណ្តាញអ្នកផ្ទុកមេរោគអេដស៍ និងបណ្តាញក្រុមប្រជាជនគន្លឹះ ដែលបានប្រឹងប្រែងបន្តចូលរួមការងារឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ ទោះបីស្ថិតក្នុងស្ថានភាពដ៏លំបាកចំពោះការប្រឈមធំៗនានាដែលបាន និងកំពុងកើតមានយ៉ាងណាក៏ដោយ។

បន្ទាប់ពីការពិភាក្សាផ្លាស់ប្តូរយោបល់ដ៏ទូលំទូលាយមក សមាជិក សមាជិកាទាំងអស់ បានប្តេជ្ញាបន្តរួមគ្នាក្នុងការប្រយុទ្ធទប់ស្កាត់ និងលុបបំបាត់ការឆ្លងរាលដាលមេរោគអេដស៍ និងក្នុងឆន្ទៈ



អាសយដ្ឋាន : អគារលេខ១៦ ផ្លូវលេខ២៧១ កែង ១៥០ សង្កាត់ទឹកល្អក់២ ខណ្ឌទួលគោក ទូរស័ព្ទ (855) 023 882 241 និង ទូរសារ (855) 23 885 129
Tel: (855) 23 882 241 · Fex: (855) 23 885 129 · E-mail: info@naaa.gov.kh · Website: naaa.gov.kh

រួមឆ្ពោះទៅសម្រេចគោលដៅ៩៥ ទី១។ កិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើក ទី២ ឆ្នាំ២០២២ បានដាក់ចេញនូវការសម្រេចចិត្តដូចតទៅ៖

១. បន្តអនុវត្តសេចក្តីសម្រេចចិត្ត នៃកិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទី១ ឆ្នាំ២០២២។

២. រៀបចំសេចក្តីសម្រេចតែងតាំងក្រុមការងារបច្ចេកទេសតាក់តែងគោលនយោបាយលុបបំបាត់ជំងឺអេដស៍ នៅឆ្នាំ២០២៥ និងចីរភាពនៃកម្មវិធីអេដស៍ ឆ្នាំ២០២៣-២០២៨ ស្របតាមលិខិតលេខ ៩២៧ សជណ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២២ របស់ទីស្តីការគណៈរដ្ឋមន្ត្រី។

៣. រៀបចំគោលនយោបាយលុបបំបាត់ជំងឺអេដស៍ នៅឆ្នាំ២០២៥ និងចីរភាពនៃកម្មវិធីអេដស៍ ឆ្នាំ២០២៣-២០២៨។

ថ្ងៃពុធ ១៥រោច ខែកត្តិក ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
ធ្វើនៅខេត្តព្រះសីហនុ ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២២

**ប្រធានអង្គប្រជុំ**
**ទេសរដ្ឋមន្ត្រី**
**ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍**

**អៀង_មូលី**